**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តឧត្តរមានជ័យ**
លេខ ០០៦ ក.ស.រ.ខ.ជ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបែងចែកភារកិច្ចជូនសមាជិកក្រុមប្រឹក្សាខេត្ត**
**ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ តាមក្រុង-ស្រុក និងមន្ទីរ អង្គភាព ស្ថាប័ន ជុំវិញខេត្ត**
**តាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យអាណត្តិទី ២**

**ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- បានឃើញព្រះរាជក្រិត្យលេខ នស/រកម/០៥១៤/៦៦១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ សមាសភាពក្រុមប្រក្រឹក្សាខេត្តឧត្តរមានជ័យ អាណតតតិទី២ ។
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងស្មារតីអង្គប្រជុំវិសាមញ្ញលើកទី២ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

**សម្រេច**

**ប្រការ១÷** ត្រូវបានបែងចែកភារកិច្ចជូន ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមប្រឹក្សាខេត្តដើម្បីជួបប្រាស្រ័យ ទាក់ទងជាមួយប្រជាពលរដ្ឋនៅតាមក្រុងស្រុកក្នុងខេត្ត និងចូលរួមប្រជុំសាមញ្ញ វិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង ស្រុក ព្រមទាំងតាមដានការអនុវត្តន៍ការងារតាមមន្ទីរ អង្គភាព ស្ថាបន័នានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត ដូចខាងក្រោម៖

| | |
|---|---|
| ១-ឯកឧត្តម **យឹម ឆិន** | ប្រធានក្រុមប្រឹក្សាខេត្ត ទទួលបន្ទុកដឹកនាំរួម។ |
| ២-ឯកឧត្តម **ខ្មៅ ឆន** | សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកចុងកាល់***និងទទួលការងារមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់និង សុរិយោដីមន្ទីរអប់រំយុវជន និងកីឡា ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការ របស់ក្រុមប្រឹក្សាខេត្ត ។ |
| ៣- ឯកឧត្តម **ជុំន ណុល** | សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ក្រុងសំរោង***និងទទួលការងារមន្ទីរប្រៃសណីយ៍មន្ទីរទំនាក់រដ្ឋសភាព្រឹទ្ធសភានិង អធិការកិច្ចមន្ទីរសាធារណៈការ និងដឹកជញ្ជូនព្រមទាំងការងារផ្សេងៗទៀតតាម តម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។ |

៤- ឯកឧត្តម **ទេន់ សុជល** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ក្រុងសំរោង*** និងទទួលការងារមន្ទីរបរិស្ថានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរពាណិជ្ជកម្ម ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

៥- ឯកឧត្តម **ឈួន អាន** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកត្រពាំងប្រាសាទ***និងទទួលការងារសាលាខេត្ត អង្គភាព ពន្ធដារ គយរដ្ឋាករ និងខណ្ឌរដ្ឋបាលព្រៃឈើ ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត ។

៦-លោកជំទាវ **សួន សាខុន** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋ នៅ ***ស្រុកចុងកាល់***និងទទួលការងារមន្ទីរកិច្ចការនារីមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ការងារអង្គការសង្គមស៊ីវិលនានាព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

៧- លោកជំទាវ **ផុន ស្រីមុំ** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ក្រុងសំរោង*** និងទទួលការងារ មន្ទីរផែនការ មន្ទីរធនធានទឹក និងឧតុនិយម ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

៨- ឯកឧត្តម **ព្រឿង ប្រុណពិត** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកអន្លង់វែង*** និងទទួលការងារមន្ទីរធម្មការនិងសាសនា មន្ទីរឧស្សាហកម្ម និងសិប្បកម្ម មន្ទីររ៉ែ និងថាមពល ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត ។

៩- ឯកឧត្តម **ជុំ ស៊ីម** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកអន្លង់វែង***និងទទួលការងារមន្ទីរទេសចរណ៍ មន្ទីរមុខងារសាធារណៈ មន្ទីរកសិកម្មព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

១០- ឯកឧត្តម **និត ស៊ន់** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកត្រពាំងប្រាសាទ*** និងទទួលការងារមន្ទីរសុខាភិបាល មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

១១-ឯកឧត្តម **ស្លោម ខ្មៅ** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកបន្ទាយអំពិល*** និងទទួលការងារមន្ទីរអភិវឌ្ឍន៍ជនបទ រតនាគារ អគ្គិសនី ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

១២- ឯកឧត្តម **ខាំ ខសាល** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកបន្ទាយអំពិល*** និងទទួលការងារអនុវត្តច្បាប់ និងពន្ធនាគារ តុលាការព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

១៣-ឯកឧត្តម **ម៉ុន គីមហេង** សមាជិកក្រុមប្រឹក្សាខេត្ត ទទួលការងារជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋនៅ ***ស្រុកត្រពាំងប្រាសាទ*** និងទទួលការងារមន្ទីរព័ត៌មាន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងការងារផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត។

**ប្រការ២ ៖** ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ក្រុមប្រឹក្សាខេត្ត ដែលបានបែងចែកភារកិច្ចដូចប្រការ១ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាខេត្តពេលប្រជុំសាមញ្ញ និងវិសាមញ្ញ ដើម្បីដោះស្រាយបញ្ហា។

***<u>អំពីតួនាទី និងភារកិច្ចសមាជិកក្រុមប្រឹក្សា</u>***

ត្រូវជួបប្រាស្រ័យទំនាក់ទំនង និង សហការការងារជាមួយ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ គណៈកម្មាធិការនានា របស់ក្រុមប្រឹក្សាតាមប្រភេទ បណ្តាអង្គភាពនានា និងជាមួយប្រជាពលរដ្ឋ លើកិច្ចការដូចខាងក្រោម ៖

- សម្របសម្រួល សហការជាមួយមន្ទីរ-អង្គភាពជំនាញក្នុងការរិះរកវិធានការឆ្លើយតប អំពីតម្រូវការនានា របស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យ របស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- សិក្សាស្វែងយល់អំពីបញ្ហា តម្រូវការចាំបាច់នានា របស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តដើម្បីស្នើដាក់បញ្ចូលក្នុងរបៀបវារៈកិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាខេត្ត ស្របតាមបទបញ្ជាផ្ទៃក្នុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន និងការផ្សព្វផ្សាយព័ត៌មាននានា ជូនក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិនានា
- ទទួលយកសំណើ សំណូមពរ តម្រូវការរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ ប្រជាពលរដ្ឋ ដើម្បីធ្វើការបូកសរុបរបាយការណ៍ និងរាយការណ៍ជូនក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ដើម្បីធ្វើអន្តរាគមន៍ និងការឆ្លើយតប ។

**អំពីសិទ្ធិរបស់សមាជិកក្រុមប្រឹក្សា**

ដើម្បីឱ្យការបំពេញភារកិច្ចទទួលបានលទ្ធផលល្អ ព្រមទាំងមានការឆ្លើយតប សមាជិកក្រុមប្រឹក្សាអាច ៖

- ចូលរួមក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និង គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាតាមប្រភេទ ដោយសុំការអនុញ្ញាតជាមុន ពីប្រធានក្រុមប្រឹក្សា និង ប្រធានគណៈកម្មាធិការទាំងនោះ លើកលែងតែការប្រជុំសម្ងាត់របស់ក្រុមប្រឹក្សានីមួយៗខាងលើ គឺមិនមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំនេះបានឡើយ
- ផ្តល់យោបល់ជូនកិច្ចប្រជុំ តាមការស្នើសុំពីប្រធានក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាតាមប្រភេទ ពីបញ្ហាប្រឈម តម្រូវការនានា និងការឆ្លើយតប ដែលបានអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត ប៉ុន្តែពុំមានសិទ្ធិអនុម័តក្នុង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាទាំងនេះឡើយ។

**ប្រការ៣ ៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤ ៖** គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលក្រុង គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ អង្គភាព ស្ថាប័ន ពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ១ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧត្តរមានជ័យ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាខេត្ត**

ជើប_ឆិន

***ចំលងជូន***

-ក្រសួងមហាផ្ទៃ
-លេខាធិការដ្ឋាន គ.ជ.អ.ប
(ដើម្បីជូនជ្រាប)
-ដូចប្រការ៤
(ដើម្បីអនុវត្ត)
-ឯកសារកាលប្បវត្តិ ។